ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D308/3/1/3

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម នេយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 08 / 2017
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ: កោសលុប

## សេចក្តីសម្រេចលើសំណើបន្ទាន់របស់ [redacted] ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAM

**សហមេធាវីរបស់ [redacted]**
ប៊ិត ស៊ាងលីម
Wayne JORDASH

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Emmanuel JACOMY
Lyma NGUYEN

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើបន្ទាន់របស់ [redacted] ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/1)" ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ ("សំណើ")[1]។

1. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ("ដីកាដំណោះស្រាយ")[2] ដោយសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយនេះ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[3]។

2. នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីរបស់ [redacted] ("សហមេធាវី") បានដាក់សំណើ។ នៅក្នុងថ្ងៃដដែលនោះដែរ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងថា គាត់ពុំមានបំណងដាក់ចម្លើយតបណាមួយឡើយ។

3. សហមេធាវីស្នើសុំពន្យារពេលមួយខែ និងបង្កើនចំនួន ៣០ សន្លឹកបន្ថែមទៀតសម្រាប់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[4]។ សហមេធាវីអះអាងថា សំណើនេះមានទាំងភាពសមហេតុផល និងភាពសមាមាត្រគ្នា ដោយគិតអំពីកាលៈទេសៈពិសេសនានា[5] ហើយពិចារណាដល់ (i) ភាពស្មុគស្មាញកម្រិតខ្ពស់ និងភាពប្លែកពីគេនៃសំណុំរឿង ពោលគឺយុត្តាធិការបុគ្គលនៅក្នុងបរិបទនៃដីកាលើកលែងការចោទប្រកាន់ និងបញ្ហាអង្គហេតុ និងអង្គច្បាប់ទូលំទូលាយដែលបានលើកឡើង

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/១") សំណើបន្ទាន់របស់ [redacted] ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/1) ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/2 ("សំណើ")។

[2] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3។

[3] សំណុំរឿង ០០៤/១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 បានជូនដំណឹងនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧។

[4] សំណើ កថាខណ្ឌ ១, ១៥-១៦។

[5] សំណើ កថាខណ្ឌ ៧។

នៅក្នុងបណ្តឹងឧទ្ធរណ៍[6] (ii) ប្រតិបត្តិការបច្ចុប្បន្នរបស់ក្រុមមេធាវីការពារក្តីនៅក្នុងសមត្ថភាពដែលត្រូវបានកាត់បន្ថយ និងការសម្រេចចិត្តរបស់សហមេធាវីអន្តរជាតិក្នុងការបង្ហាញខ្លួនក្នុងតុលាការសម្រាប់សំណុំរឿងមួយផ្សេងទៀត ដោយផ្អែកលើកាលបរិច្ឆេទដំបូងនៃគម្រោងបញ្ចប់ផែនការ ដែលបានកែសម្រួល[7] និង (iii) កង្វះសមត្ថភាពក្នុងការបកប្រែចម្លើយតប តាមកាលបរិច្ឆេទដែលបានកំណត់[8]។ សហមេធាវីគូសបញ្ជាក់ថា ទោះបីជាបណ្តឹងឧទ្ធរណ៍នេះមានចំនួនតិចទំព័រ (២៩ ទំព័រ) ក៏ដោយ ក៏បណ្តឹងឧទ្ធរណ៍នេះបានប្រើប្រាស់នូវធនធានសន្លឹកសន្ធាប់របស់សហព្រះរាជអាជ្ញា ហើយថា ដើម្បីដាក់ចម្លើយតបមួយឱ្យបានទូលំទូលាយ គឺតម្រូវឱ្យមានការពិនិត្យគ្រប់ជ្រុងជ្រោយ និងការវិភាគទៅលើសម្ភារតឹកតាងដ៏សន្ធឹកសន្ធាប់[9]។

4. អនុលោមតាមវិធាន ៣៩(២) និង (៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់ និង/ឬពន្យារពេលវេលាកំណត់សម្រាប់ដាក់ឯកសារនានា ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍។ ផ្អែកតាមសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ មាត្រា ៥(៤) អង្គជំនុំជម្រះក៏អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស។ នៅក្នុងករណីបច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះយល់ឃើញថាជាការសមស្របក្នុងការអនុញ្ញាតតាមសំណើសុំពន្យារពេលវេលាដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៧[10] នោះ ដោយពិចារណាទៅលើវិសាលភាព និងសារសំខាន់នៃបញ្ហាអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ, សមត្ថភាពបំពេញការងារនាពេលបច្ចុប្បន្នរបស់ក្រុមមេធាវីការពារក្តី ដោយសារមានការកែសម្រួលកាលបរិច្ឆេទនៃរឿងក្តី ព្រមទាំងបញ្ហាជាប់គាំងនៃការបកប្រែ។ ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនជឿថា បណ្តឹងឧទ្ធរណ៍នោះមានភាពស្មុគស្មាញមែនទែន ដែលទាមទារឱ្យសហមេធាវីត្រូវធ្វើចម្លើយតបមួយឱ្យបានទូលំទូលាយដែលមានចំនួនទំព័រទ្វេដង (៦០ទំព័រ) នោះឡើយ។ ប៉ុន្តែ ដោយពិចារណាទៅលើសារសំខាន់នៃរឿងក្តីចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក, សេចក្តីពន្យល់ ដែលថាពាក់ព័ន្ធការ

---

[6] សំណើ កថាខណ្ឌ ៨-១១។

[7] សំណើ កថាខណ្ឌ ១២-១៣។

[8] សំណើ កថាខណ្ឌ ១៤។

[9] សំណើ កថាខណ្ឌ ៩-១០។

[10] កាលបរិច្ឆេទដែលបានស្នើឡើង ក្នុងសំណើសុំ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧ ជាថ្ងៃឈប់សម្រាកបុណ្យជាតិ នៅអ.វ.ត.ក។

ស្រាវជ្រាវយ៉ាងល្អិតល្អន់ ការវិភាគក្នុងការព្រាងចម្លើយតប និងការណ៍ដែលគ្មានការជំទាស់ពីភាគីផ្សេងទៀតនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការអនុញ្ញាតឱ្យបង្កើនចំនួន ១៥ ទំព័របន្ថែមទៀត គឺជាការសមស្របសម្រាប់កាលៈទេសៈពិសេស។

**យោងលើសំអាងហេតុខាងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

- **ទទួលយក** ផ្នែកខ្លះនៃសំណើ។
- **អនុញ្ញាត** ឱ្យសហមេធាវីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ត្រឹមថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧។
- **អនុញ្ញាត** ឱ្យបង្កើនចំនួន ១៥ ទំព័រ បន្ថែមទៀត សម្រាប់ចម្លើយតបរបស់សហមេធាវី

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះ បិទផ្លូវតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** Olivier BEAUVALLET **ន៉ីយ ថុល** Kang Jin BAIK **ហួត វុទ្ធី**